នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះសាលាដំបូង |
| **ថ្ងៃដាក់** | : | ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 29-Sep-2015, 15:23
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ** អមដោយ **ឧបសម្ព័ន្ធសម្ងាត់បំផុត ៤**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង:** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

**ការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវឯកសារមួយចំនួនពីសំណុំរឿង០០៤ ដែលពាក់ព័ន្ធនឹងសំណុំរឿង០០២ អនុលោមតាមសំណុំរឿង០០៤-D193/43 និងសំណុំរឿង004-D193/44**

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា**
លោក Nicholas KOUMJIAN

**ចម្លងជូន:**
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន
ចៅក្រម Claudia FENZ
ចៅក្រម យូរ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
លោកស្រី Marie GUIRAUD

**ចម្លងជូន:**
**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្ដីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោក Arthur VERCKEN
លោកស្រី Anta GUISSÉ

**មេធាវីប្រចាំការ:**

លោកស្រី ទូច វរល័ក្ស
លោក Calvin SAUNDERS

**សហចៅក្រមស៊ើបអង្កេត**
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Michael BOHLANDER

# I. ការដាក់បង្ហាញ

1. សហព្រះរាជអាជ្ញាអន្តរជាតិ (“សហព្រះរាជអាជ្ញា”) សូមដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួនដប់មួយ(១១)ដែលបានទទួលយករួចហើយនៅក្នុងសំណុំរឿង០០៤ ដែលពាក់ព័ន្ធទៅនឹងសវនាការក្នុងសំណុំរឿង០០២ (“សម្ភារៈ”)។ សម្ភារៈទាំងនេះសុទ្ធតែបានកំណត់អត្តសញ្ញាណនៅក្នុង **ឧបសម្ព័ន្ធ ១** សម្ងាត់បំផុត។ ដូចបានកំណត់អត្តសញ្ញាណនៅក្នុងឧបសម្ព័ន្ធនេះ សហព្រះរាជអាជ្ញាក៏សូមធ្វើការកំណត់ជាបឋមទាក់ទងនឹងឯកសារទាំងនេះ ដែលសហព្រះរាជអាជ្ញាអាចស្វែងរកការអនុញ្ញាតសុំឱ្យទទួលយកស្របតាមវិធាន ៨៧(៣) និង(៤)។ ប៉ុន្តែ ការកំណត់នេះមិនមែនជាចុងក្រោយទេ ហើយក៏អាចនឹងមានការផ្លាស់ប្តូរដែរ។

2. សហព្រះរាជអាជ្ញា សូមស្នើការអនុញ្ញាតដាក់បង្ហាញសម្ភារៈទាំងឡាយ ដែលបានបញ្ចូលនៅក្នុងសំណើសុំដាក់បង្ហាញនេះ តាមរយៈសំណើសុំចំនួនពីរ(សំណើទាំងពីររួមគ្នាហៅថា“សំណើ”) ដែលបានដាក់ជូនសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី១៧ ខែកញ្ញា[1] និងថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥[2]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (សចសអ) បានអនុញ្ញាតតាមសំណើ នៅថ្ងៃទី២៨[3] និង២៩ ខែកញ្ញា ឆ្នាំ២០១៥[4]។ សេចក្តីសម្រេចទាំងនេះ ត្រូវបានចែកជូនដល់អង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃចេញ។ ឯកសារចំនួនពីរដែលបានបញ្ចូលនៅក្នុងសំណើ ក៏ទទួលបានការអនុម័តយល់ព្រមឱ្យដាក់បង្ហាញតែក្នុងទម្រង់កោសលុបប៉ុណ្ណោះ។ ឯកសារមួយក្នុងចំណោមឯកសារទាំងនេះត្រូវបានដាក់ភ្ជាប់ទៅជាមួយជាភាសាខ្មែរ និងអង់គ្លេសក្នុង **ឧបសម្ពន្ធ ២** និង **៣ សម្ងាត់បំផុត**។ ឯកសារផ្សេងទៀតត្រូវបានដាក់ភ្ជាប់ជាភាសាខ្មែរក្នុង **ឧបសម្ពន្ធ ៤** និងសំណៅបកប្រែជាភាសាអង់គ្លេស នឹងផ្តល់ជូនក្នុងពេលឆាប់ៗតាមដែលអាចរកបាន។

---

[1] សំណុំរឿង004-**D193/40** សំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីនៃសំណុំរឿងលេខ០០៤ ដែលពាក់ព័ន្ធនឹងចាម ទៅក្នុងសំណុំរឿងលេខ០០២, ១៧ កញ្ញា ២០១៥។

[2] សំណុំរឿង004-**D193/42** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិកាលពីខែកញ្ញា ឆ្នាំ២០១៥ សុំដាក់បង្ហាញកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីនៃសំណុំរឿងលេខ០០៤ ទៅក្នុងសំណុំរឿងលេខ០០២, ២៥ ខែកញ្ញា ឆ្នាំ២០១៥។

[3] សំណុំរឿង 004-**D193/43** សេចក្តីសម្រេចលើសំណើសុំដាក់បង្ហាញឯកសារ D193/40 របស់សហព្រះរាជអាជ្ញាអន្តរជាតិ, ២៨ កញ្ញា ២០១៥។

[4] សំណុំរឿង004-**D193/44** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំបង្ហាញឯកសារសំណុំរឿង០០២ ឯកសារ D193/42 ចុះថ្ងៃទី២៩ កញ្ញា ២០១៥។

3. អង្គជំនុំជម្រះសាលាដំបូងបានថ្លែងថា កាតព្វកិច្ចដើម្បីបង្ហាញសម្ភារៈពាក់ព័ន្ធ ទោះជាដាក់បន្ទុក ឬដោះបន្ទុកក្តី គឺជាកាតព្វកិច្ចមួយដែលត្រូវជាប់ជំពាក់ទៅអង្គជំនុំជម្រះសាលាដំបូង ក៏ដូចគ្នាទៅនឹងជនជាប់ចោទដែរ ដោយហេតុថា "ជាប្រយោជន៍ដែលនាំដល់ការស្វែងរកការពិត បើអង្គជំនុំជម្រះមានសិទ្ធិចូលពិនិត្យមើលឯកសារទាំងនេះ"[5]។ ជាងនេះទៀត អង្គជំនុំជម្រះនេះធ្លាប់បានសម្រេចពីមុនថា "វិធាន៥៣(៤) នៃវិធានផ្ទៃក្នុង ដាក់កាតព្វកិច្ចជាបន្តបន្ទាប់ទៅលើសហព្រះរាជអាជ្ញាក្នុងការបង្ហាញជូនអង្គជំនុំជម្រះសាលាដំបូង នូវសម្ភារៈណាមួយដែលកំពុងស្ថិតនៅក្រោមការកាន់កាប់របស់ខ្លួន ដែលអាចជានត្ថិភាពនៃពិរុទ្ធ ឬសម្រាលពិរុទ្ធភាពរបស់ជនជាប់ចោទ ឬអាចមានឥទ្ធិពលទៅលើភាពជឿជាក់បាននៃភស្តុតាង"[6]។ អង្គជំនុំជម្រះសាលាដំបូង បានណែនាំថា ជាដំបូងសហព្រះរាជអាជ្ញាត្រូវដាក់សំណើសុំបង្ហាញរបស់ខ្លួនទៅអង្គជំនុំជម្រះ ដោយប្តឹងពីភស្តុតាងដែលខ្លួនចង់ដាក់បង្ហាញ បន្ទាប់មកទើបដាក់សំណើទៅអង្គជំនុំជម្រះសាលាដំបូង សុំឱ្យទទួលយកឯកសារទាំងនោះ ទុកជាការអនុម័តសម្រាប់ការដាក់បង្ហាញឯកសារ[7]។

4. អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានបង្គាប់ពីមុនថា គ្រប់ការដាក់បង្ហាញឯកសារទាំងអស់ពីសំណុំរឿង០០៣ និង០០៤ ទៅក្នុងសំណុំរឿង០០២ គប្បីដាក់ និងជូនដំណឹងទៅអង្គជំនុំជម្រះសាលាដំបូងជាបណ្តោះអាសន្នដោយឈរលើមូលដ្ឋានសម្ងាត់បំផុត និងថាបន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការកំណត់ចំពោះឯកសារនោះ ថាតើ គប្បីដាក់ចំណាត់ថ្នាក់ឡើងវិញថា សម្ងាត់ ឬក៏អត់[8]។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង អំពីកំណត់ហេតុដែលមាននៅក្នុង **ឧបសម្ព័ន្ធ ១** ដោយឈរលើមូលដ្ឋានសម្ងាត់បំផុត។

---

[5] **E127/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "ការបង្ហាញអំពីចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២", ២៤ មករា ២០១២។

[6] *ដដែលដូចខាងលើ,* ទំព័រ១។

[7] **E127/7/1** ព័ត៌មានពាក់ព័ន្ធនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង០០៣ និង០០៤ ដែលអាចពាក់ព័ន្ធនឹងសំណុំរឿង ០០២, ១៦ សីហា ២០១៣, កថាខណ្ឌ២។

[8] **E127/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "ការបង្ហាញអំពីចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២", ២៤ មករា ឆ្នាំ២០១២, ទំព័រ១។

5. ការផ្តល់សិទ្ធិឲ្យដាក់បង្ហាញឯកសារគឺស្ថិតនៅក្រោមការដាក់កម្រិត និងលក្ខខណ្ឌតម្រូវមួយចំនួន ដែលត្រូវបានកំណត់នៅក្នុងការដាក់បង្ហាញពីមុនរបស់សហព្រះរាជអាជ្ញា[9]។

6. ដោយគោរពតាមការដាក់កម្រិតទាំងអស់នេះ សហព្រះរាជអាជ្ញានឹងធ្វើយ៉ាងណាឲ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មេធាវីការពារក្តី នួន ជា មេធាវីការពារក្តី ខៀវ សំផន និង មេធាវីប្រចាំការរបស់ ខៀវ សំផន បានទទួលសម្ភារៈទាំងនេះជាសំណៅអេឡិចត្រូនិក តាមរយៈហ្វូលឌ័ររួម ដល់គ្រប់ភាគីទាំងអស់ឲ្យបានឆាប់តាមដែលអាចធ្វើបាន។

## II. ដំណោះស្រាយដែលស្នើឡើង

7. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងទទួលយក និងដាក់បញ្ចូលទៅក្នុងសំណុំរឿង០០២ នូវកំណត់ហេតុស្តាប់ចម្លើយ ដូចបានកំណត់អត្តសញ្ញាណក្នុង **ឧបសម្ព័ន្ធ ១**៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |

[9] សូមមើល ឯទ. E319/24 ការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នូវឯកសារមួយចំនួនពីសំណុំរឿងលេខ០០៤ ដែលពាក់ព័ន្ធនឹងសំណុំរឿង០០២ អនុលោមតាមសំណុំរឿង០០៤-D193/24 ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៥ កថាខណ្ឌ៥។